# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខៈ ០៧៣ MIH / 2015

# ប្រកាស
## ស្តីពីការបង្កើតក្រុមការងារវិមជ្ឈការ-វិសហមជ្ឈការ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១ ៖** បង្កើតក្រុមការងារវិមជ្ឈការ-វិសហមជ្ឈការ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម គឹម ទូច | រដ្ឋលេខាធិការ | ប្រធាន |
| ២- | ឯកឧត្តម អ៊ិច បូរ៉ា | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣- | ឯកឧត្តម អ៊ុំ សុផា | អគ្គនាយកកិច្ចការទូទៅ | សមាជិក |
| ៤- | ឯកឧត្តម សឹម ណារ៉ា | អគ្គនាយកឧស្សាហកម្ម | សមាជិក |
| ៥- | លោកជំទាវ ពៅ វរលក្ស្មណ៍ | អគ្គនាយិកាសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម | សមាជិក |
| ៦- | ឯកឧត្តម ចាន់ បូរិន្ទ | ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា | សមាជិក |
| ៧- | ឯកឧត្តម ឡាំ គឹមឡេង | ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | សមាជិក |

**ប្រការ២៖** បង្កើតក្រុមជំនួយការបច្ចេកទេសនៃក្រុមការងារវិមជ្ឈការ-វិសហមជ្ឈការដែលមានសមាសភាពដូចខាងក្រោម៖



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣ ៤២៨ ២៦៣
អ៊ីម៉ែល: mih.smcabinet@gmail.com

**- នាយកដ្ឋានបុគ្គលិក**

១- កញ្ញា បុត្រ ភ័ក្រ្តសត្យា ប្រធាននាយកដ្ឋាន ប្រធានសម្របសម្រួល

២- លោក ឡុង បូរ៉ា អនុប្រធាននាយកដ្ឋាន សមាជិកទទួលបន្ទុកលេខាធិការ

**- នាយកដ្ឋានរដ្ឋបាល**

១- លោក ពៅ វណ្ណដា ប្រធាននាយកដ្ឋាន សមាជិក

**- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ**

១- លោក ញ៉ែម ចន្ទូ ប្រធាននាយកដ្ឋាន សមាជិក

២- លោក ស៊ឹម មករា ប្រធានការិយាល័យ សមាជិក

**- នាយកដ្ឋាននីតិកម្ម**

១- លោក ចេង លឹមជី ប្រធាននាយកដ្ឋាន សមាជិក

២- លោក ទឹង សេរីវុធ អនុប្រធាននាយកដ្ឋាន សមាជិក

**- តំណាងអគ្គនាយកដ្ឋានឧស្សាហកម្ម**

១- លោក ប៊ី ពិទូរ្យ អគ្គនាយករង សមាជិក

២- លោក ហ៊ិត ផេង ប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម សមាជិក

**- តំណាងអគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម**

១- លោក ហេង សោភ័ណ្ឌ អគ្គនាយករង សមាជិក

២- លោក នួន សុភ័ណ្ឌ អនុប្រធាននា.ផែនការ និងជំរុញការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម សមាជិក

**- តំណាងវិទ្យាស្ថានស្តង់ដាកម្ពុជា**

១- លោក ចាន់ សុផា អនុប្រធានវិទ្យាស្ថាន សមាជិក

២- លោក សេង ឆាង ប្រធាននាយកដ្ឋានវិញ្ញាបនបត្រកម្ម សមាជិក

**- តំណាងមជ្ឈមណ្ឌលមាត្រាសាស្រ្តជាតិ**

១- លោក គឹម ចន្ទតារា អនុប្រធានមជ្ឈមណ្ឌល សមាជិក

២- លោក វ៉ាន់ ម៉ៅ ប្រធាននាយកដ្ឋាននីត្យានុកូលមាត្រាសាស្រ្ត សមាជិក

**ប្រការ៣** ៖ ក្រុមការងារ និងក្រុមជំនួយការបច្ចេកទេសវិមជ្ឈការ-វិសហមជ្ឈការមានភារកិច្ចដូចតទៅ៖

- ចូលប្រជុំការងារវិមជ្ឈការ-វិសហមជ្ឈការ និងអនុវត្តតាមគោលការណ៍របស់រាជរដ្ឋាភិបាល
- ក្តាប់ផែនការ ទិសដៅ គោលនយោបាយនៃការប្រជុំរាល់ពេល
- រៀបចំឯកសារលិខិតបទដ្ឋាននានា និងនីតិវិធីការងារដែលជាការងារពាក់ព័ន្ធដល់ការកែទម្រង់ការងារក្នុងក្របខ័ណ្ឌនៃការអនុវត្តវិមជ្ឈការ-វិសហមជ្ឈការរបស់ក្រសួង
- ធ្វើសេចក្តីរាយការណ៍ជូន **ប្រធានស្ថាប័ន** ដើម្បីជ្រាប និងស្នើសុំមតិណែនាំ ឬ សម្រេច និង/ឬ សុំការណែនាំរាល់ការងារទាំងឡាយដែលពាក់ព័ន្ធដល់ការផ្ទេរ «**មុខងារ ការទទួលខុសត្រូវសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ**»
- ក្រុមជំនួយការបច្ចេកទេស ត្រូវចូលរួមប្រជុំតាមការកំណត់របស់ក្រុមការងារវិមជ្ឈការ-វិសហមជ្ឈការ ព្រមទាំងចូលរួមរាល់ការប្រជុំអន្តរក្រសួង ឬ ប្រជុំថ្នាក់ជាតិ ដើម្បីរាយការណ៍ជូនអគ្គនាយកដ្ឋាន វិទ្យាស្ថាន និងមជ្ឈមណ្ឌល បានជ្រាប និងតាមដំណាក់កាលនីមួយៗ។

**ប្រការ៤** ៖ ប្រកាសលេខ ៦៥៣ ឧវថ.បល.ប្រក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២ ស្តីពីការបង្កើតក្រុមការងារ វិមជ្ឈការ-វិសហមជ្ឈការរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥** ៖ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានបុគ្គលិក គ្រប់អង្គភាពពាក់ព័ន្ធ និងសាមីជន ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ២០១៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល** ៖

-ក្រសួងមហាផ្ទៃ

-ក្រសួងមុខងារសាធារណៈ

« *ដើម្បីជូនជ្រាប* »

-គ្រប់នាយកដ្ឋាន និងអង្គភាពថ្នាក់ស្មើ

-គ្រប់មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត

-ដូចប្រការ៥ « *ដើម្បីអនុវត្ត* »

-ឯកសារ-កាលប្បវត្តិ